ជំពូកទី៤៖ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

៤.១ សេចក្តីផ្តើម

ការសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងណាមួយ វាជាការចាំបាច់ណាស់ក្នុងការយល់ដឹងអំពីស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គម្រោងពោលគឺមានអ្វីខ្លះដែលអាចនឹងទទួលរងផលប៉ះពាល់ ហើយមានអ្វីខ្លះដែលកំពុងតែរងការប៉ះពាល់ស្រាប់រួចមកហើយ។ ក្នុងគោលបំណងនេះ ក្រុមការងារបានសិក្សាលើទិន្នន័យមានស្រាប់ និងស្រង់ទិន្នន័យចាំបាច់មួយចំនួនដោយផ្ទាល់នៅតំបន់គោលដៅ តាមរយៈការសិក្សាលើធាតុបរិស្ថានសំខាន់ៗចំនួនបីគឺ បរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងបរិស្ថានសង្គម-សេដ្ឋកិច្ច នៅតាមគន្លងខ្សែបញ្ជូនអគ្គិសនីពីអនុស្ថានីយ៍ខាងលិចភ្នំពេញទៅអនុស្ថានីយ៍ស្ទឹងហាវ។ ការសិក្សាពីធនធានបរិស្ថានដែលមានស្រាប់នេះ មានសារៈសំខាន់ក្នុងការបញ្ជាក់ពីស្ថានភាពដើមរបស់តំបន់មុនពេលគម្រោងដំណើរការ ហើយការប្រៀបធៀបស្ថានភាពបរិស្ថាន ពេលគម្រោងដំណើរការ អាចឱ្យគេដឹងពីទំហំនៃផលប៉ះពាល់ដែលកើតមាន និងកម្រិតនៃផលប៉ះពាល់ទាំងនោះ។ ការកែប្រែណាមួយនៃធនធានបរិស្ថាននៅក្នុងតំបន់ អាចជាមូលហេតុបណ្តាលមកពីដំណើរការរបស់គម្រោងអភិវឌ្ឍន៍នេះ ហេតុនេះការសិក្សាព័ត៌មាន ឬធនធានបរិស្ថានមានស្រាប់របស់តំបន់គម្រោងជាការចាំបាច់ និងមានប្រយោជន៍សម្រាប់ដំណើរការត្រួតពិនិត្យនៅពេលដែលគម្រោងដំណើរការ និងពេលបញ្ចប់គម្រោង។

៤.២ ធនធានរូបសាស្ត្រ

៤.២.១ ម៉ានលេខា (រយៈកម្ពស់)

ម៉ានលេខារបស់បង្គោលខ្សែភ្លើងនីមួយៗ នៃគន្លងខ្សែបញ្ជូន ត្រូវប្រើប្រាស់ទិន្នន័យរយៈកម្ពស់ Digital Elevation Model (DEM) ដែលមានកម្រិតច្បាស់ (Spatial Resolution) ៣០ម៉ែត្រ គុណ ៣០

Draft


#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ម៉ែត្រ កំណែថ្មី ២ (Version 2) របស់ស្ថាប័ន United State Geology Survey (USGS) http://www.usgs.gov/។ ស្ថិតិពណ៌នាត្រូវបានប្រើប្រាស់ក្នុងការបកស្រាយទិន្នន័យហានលេខារបស់បង្គោលខ្សែភ្លើងសរុបទាំង៤២៦បង្គោល។

សណ្ឋានដីទូទៅនៃគម្រោងបញ្ជូនខ្សែអគ្គិសនីដែលមានតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍ស្ទឹងហាវ ខេត្តព្រះសីហនុ ទៅអនុស្ថានីយ៍រាជធានីភ្នំពេញ មានរយៈកម្ពស់កើនឡើងចាប់ពី ២ម៉ែត្រ ទៅ ១៦១ម៉ែត្រពីនីវ៉ូទឹកសមុទ្រ។ រយៈកម្ពស់ជាមធ្យមរបស់បង្គោលខ្សែភ្លើងសរុបទាំង ៤២៦បង្គោល ដោយចាប់ពីបង្គោលខ្សែភ្លើងដំបូង (T001-WPP) រហូតដល់បង្គោលខ្សែភ្លើងចុងក្រោយ (T426-5TH) មានរយៈកម្ពស់ ៣៨ម៉ែត្រ ពីនីវ៉ូទឹកសមុទ្រ។ បង្គោលខ្សែបញ្ជូនអគ្គិសនីដែលមានទីតាំងនៅពីលើសណ្ឋានដីដែលមានរយៈកម្ពស់ទាបជាង ១០ម៉ែត្រពីនីវ៉ូទឹកសមុទ្រមានចំនួន ៩០បង្គោល និងរយៈកម្ពស់ខ្ពស់ជាង ១០០ម៉ែត្រពីនីវ៉ូទឹកសមុទ្រមានចំនួន ៣១បង្គោល។

ចំណែកឯបង្គោលខ្សែភ្លើងឆ្លងកាត់ខេត្តកំពង់ស្ពឺមានចំនួន ៣០៨បង្គោល ដែលមានរយៈកម្ពស់អប្បបរមាគឺ ១០ម៉ែត្រលើនីវ៉ូទឹកសមុទ្រ រយៈកម្ពស់អតិបរមាគឺ ១៦១ ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ រយៈកម្ពស់ជាមធ្យមគឺ ៦១,៤៣ ម៉ែត្រលើនីវ៉ូទឹកសមុទ្រ និងមានរយៈកម្ពស់ជាស្តង់ដារគម្លាតគម្រូគឺ ៣៣,៨១ ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ ខេត្តកោះកុងមានចំនួន ៧២ បង្គោល ដែលមានរយៈកម្ពស់អប្បបរមាគឺ ២ម៉ែត្រលើនីវ៉ូទឹកសមុទ្រ កម្ពស់អតិប្បរមាគឺ ៩២ ម៉ែត្រលើនីវ៉ូទឹកសមុទ្រ កម្ពស់ជាមធ្យមគឺ ១៥,៩៥ម៉ែត្រលើនីវ៉ូទឹកសមុទ្រ និងមានរយៈកម្ពស់ជាស្តង់ដារគម្លាតគម្រូគឺ ១៤.៣៥១៥៦៧ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ ក្រុងព្រះសីហនុមានចំនួន ៤៦បង្គោល ដែលមានរយៈកម្ពស់អប្បបរមាគឺ ៣ ម៉ែត្រលើនីវ៉ូទឹកសមុទ្រ រយៈកម្ពស់អតិប្បរមាគឺ ៤៦ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។ រយៈកម្ពស់ជាមធ្យមគឺ ១០,៨៨ម៉ែត្រលើនីវ៉ូទឹកសមុទ្រ និងមានរយៈកម្ពស់ជាស្តង់ដារគម្លាតគំរូគឺ ៨,១៤ម៉ែត្រលើនីវ៉ូទឹកសមុទ្រ។

Draft



Draft

រូបភាព៤.១៖ រយៈកម្ពស់ដែលបង្ហោលខ្សែភ្លើងត្រូវសាងសង់

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៤.២.២ ធរណីសាស្ត្រ

ក្នុងការទាញយក (Extract) ព័ត៌មានភូគព្ភសាស្ត្រនៃតំបន់សិក្សា ត្រូវបានធ្វើការពង្រីក (Buffer) ជុំវិញអ័ក្ស (Axis) នៃតំបន់សាងសង់គ្រឹះដែលមានកាំ (Radius) ៣០ម៉ែត្រ (២៨១៥ម៉ែត្រការ៉េ) របស់បង្គោលខ្សែអគ្គិសនីនីមួយៗ។ ការសិក្សាភូគព្ភសាស្ត្ររបស់បង្គោលភ្លើងនៃគន្លងខ្សែបញ្ជូន និងអនុស្ថានីយ៍ត្រូវបង្ហាញដោយផ្អែកលើទិន្នន័យរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដែលធ្វើការប្រមូលនឹងរៀបចំដោយភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន (JICA)។


ជាលទ្ធផលបានបង្ហាញថា ចាប់ពីបង្គោលខ្សែភ្លើងដំបូង (T001-WPP) រហូតដល់បង្គោលខ្សែភ្លើងចុងក្រោយ (T426-5TH) ត្រូវបានសាងសង់លើភូគព្ភសាស្ត្រចំនួន០៤ប្រភេទ រួមមាន (១) Jurassic-Cretaceous Sandstone (២) Old Alluvium (៣) Young Alluvium និង(៤) Triassic Sandstone។

ប្រភេទភូគព្ភសាស្ត្រដែលមានផ្ទៃដីច្រើនលើសលប់គឺប្រភេទ Young Alluvium មានទំហំ៦២ហិកតា និងភូគព្ភសាស្ត្រដែលមានផ្ទៃដីតិចជាងគេគឺ Triassic Sandstone មានទំហំ១ហិកតា។ ចំនែកប្រភេទភូគព្ភសាស្ត្រ០២ប្រភេទផ្សេងទៀតគឺ Old Alluvium មានទំហំ៣១ហិកតា និងJurassic-Cretaceous Sandstone មានទំហំ២៥ហិកតា។

Draft

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



Draft

រូបភាព៤.២៖ ប្រភេទភូគព្ភសាស្ត្រដែលបង្ហាលអគ្គិសនីឆ្លងកាត់

Draft

៤.២.៣ ប្រភេទដី

ការសិក្សាប្រភេទដីត្រូវបានប្រើប្រាស់វិធីសាស្ត្រទាញយកទិន្នន័យ ដោយធ្វើការពង្រីកជុំវិញអ័ក្សនៃតំបន់សាងសង់គ្រឹះដែលមានកាំ ៣០ម៉ែត្រ (២៨១៥ម៉ែត្រការ៉ែ) នៃតំបន់ភូមិសាស្ត្ររបស់បង្គោលខ្សែភ្លើងនីមួយៗ។ ការសិក្សាប្រភេទដីនៃតំបន់សិក្សា ត្រូវប្រើប្រាស់ទិន្នន័យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរៀបចំដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបន្ទាប់ពីលោក Crocker (១៩៦២)។

តាមរយៈវិធីសាស្ត្រខាងលើបានបង្ហាញថា បង្គោលខ្សែភ្លើងត្រូវបានសាងសង់លើប្រភេទដីចំនួន **៩ប្រភេទ** ផ្សេងៗគ្នា រួមមានប្រភេទដី Red-Yellow Podzols មានទំហំ ២៩ហិកតា Acid Lithosols មានទំហំ ២៥ ហិកតា Grey Hydromorphics មានទំហំ ១៧ហិកតា Coastal Complex មានទំហំ ១៤ហិកតា Cultural Hydromorphics មានទំហំ១១ហិកតា Alluvial Lithosols មានទំហំ១០ហិកតា Planosols មានទំហំ៦ហិកតា Alumisols មានទំហំ៥ហិកតា និង Plinthite Podzols មានទំហំ៣ហិកតា។

ចំពោះប្រភេទភូគព្ភសាស្ត្រនិងទំហំផ្ទៃដីសរុបនៃបង្គោលខ្សែភ្លើងនីមួយៗ ដែលឆ្លងកាត់ខេត្តកំពង់ស្ពឺ ខេត្តកោះកុង និងខេត្តព្រះសីហនុត្រូវបានរាយនាមដូចខាងក្រោម៖

- ចាប់ពីបង្គោល T001-WPP ដល់ T219 ក្នុងខេត្តកំពង់ស្ពឺត្រូវបានសាងសង់លើប្រភេទដីចំនួន ០៧ ប្រភេទ រួមមានប្រភេទដី Red-Yellow Podzols មានទំហំ១៥ហិកតា Acid Lithosols មានទំហំ ១២ហិកតា Cultural Hydromorphics មានទំហំ១១ហិកតា Grey Hydromorphics មានទំហំ៨ ហិកតា Alluvial Lithosols មានទំហំ៦ហិកតា Planosols មានទំហំ៦ហិកតា និង Plinthite Podzols មានទំហំ៣ហិកតា។
- បង្គោល T220-AP16 ដល់ T382 ក្នុងខេត្តកោះកុងត្រូវបានសាងសង់លើប្រភេទដីចំនួន ០៦ ប្រភេទដែលក្នុងនោះមាន Coastal Complex មានទំហំ១៣ហិកតា Acid Lithosols មានទំហំ៨ ហិកតា Red-Yellow Podzols មានទំហំ៨ហិកតា Grey Hydromorphics មានទំហំ៨ហិកតា Alumisols មានទំហំ៥ហិកតា និងAlluvial Lithosols មានទំហំ៤ហិកតា។
- បង្គោល T383 ដល់ T426-5TH ក្នុងខេត្តព្រះសីហនុឆ្លងត្រូវបានសាងសង់លើប្រភេទដីចំនួន ០៣ ប្រភេទគឺ Red-Yellow Podzols មានទំហំ៦ហិកតា Acid Lithosols មានទំហំ៥ហិកតា និងCoastal Complex មានទំហំ១ហិកតា។

Draft


Draft


Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St 271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ផែនទីបង្ហាញប្រភេទដី

MAP OF SOIL TYPE





Legend

- Tower
- Kampong Speu
- Kon Kong
- Preah Sihanouk

Soil type

- Acid Lithosols
- Alluvial Lithosols
- Alumisols
- Basic Lithosols
- Brown Alluvial Soils
- Brown hydromorphics
- Coastal Complex
- Cultural hydromorphics
- Great Lake
- Grey hydromorphics
- Lacustrine Alluvial Soils
- Latosols
- Planosols
- Plinthite podzols
- Plinthitic hydromorphics
- Red-yellow podzols
- Regurs

Draft


គម្រោង: ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុតពីអនុស្ថានីយ៍ស្ទឹងកោះ ទៅអនុស្ថានីយ៍ភ្នំពេញខាងលិចតាមដងទន្លេមេគង្គ PROJECT: HIGH VOLTAGE 230KV TRANSMISSION LINE PROJECT FROM SEN SOK TO WEST PHNOM PENH SUBSTATION

រូបភាព៩.៣: ប្រភេទដីនៃលបង្គោលអគ្គិសនីឆ្លងកាត់


Draft

៤.២.៤ ជលសាស្ត្រ

ការសិក្សាជលសាស្ត្ររបស់តំបន់សិក្សាត្រូវបានពង្រីកចម្ងាយ ១០០ម៉ែត្រ ពីអ័ក្សរបស់បង្គោលខ្សែភ្លើងនីមួយៗ។ រាល់ទន្លេរលេខសម្គាល់បង្គោលភ្លើង និងឈ្មោះនៃប្រព័ន្ធផ្លូវទឹកទាំងឡាយណា ដែលនៅមិនឆ្ងាយជាង ១០០ម៉ែត្រ ពីតំបន់ដែលបង្គោលភ្លើងត្រូវបានសាងសង់ត្រូវបានរាយនាម។ ធ្វើការពិពណនាពីចម្ងាយដែលជិតបំផុតពីប្រព័ន្ធផ្លូវទឹកនឹងតំបន់ដែលបង្គោលត្រូវសាងសង់។ ការសិក្សាជលសាស្ត្រនេះ ប្រើប្រាស់ទិន្នន័យភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន (JICA) ក្នុងឆ្នាំ ២០០៣ និងការចុះសិក្សារបស់ក្រុមការងារបានបង្ហាញថាបង្គោលខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍អគ្គិសនីខេត្តកំពង់ស្ពឺ ទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ។




រូបភាព៤.៤៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T038AP3-T039



រូបភាព៤.៥៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T274-T275


#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៦៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T294-T295




រូបភាព៤.៧៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T342-T343




រូបភាព៤.៨៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T344-T346

Draft


#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៩៖ ចំណុចឆ្លងកាត់ប្រទុក្ខារ បុស្តឹងនៃបង្គោល T350-T351




រូបភាព៤.១០៖ ចំណុចឆ្លងកាត់ប្រទុក្ខារ បុស្តឹងនៃបង្គោល T367AP21-T368




រូបភាព៤.១១៖ ចំណុចឆ្លងកាត់ប្រទុក្ខារ បុស្តឹងនៃបង្គោល T369-T370

Draft


#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.១២៖ ចំណុចឆ្លងកាត់ប្រមុំរាយ ប៉ុស្តិ៍ងនៃបង្គោល T383-T385




រូបភាព៤.១៣៖ ចំណុចឆ្លងកាត់ប្រមុំរាយ ប៉ុស្តិ៍ងនៃបង្គោល T395AP24-T396




រូបភាព៤.១៤៖ ចំណុចឆ្លងកាត់ប្រមុំរាយ ប៉ុស្តិ៍ងនៃបង្គោល T397-T398


Draft



រូបភាព៤.១៥៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T400-T401



រូបភាព៤.១៦៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T408-T410



រូបភាព៤.១៧៖ ចំណុចឆ្លងកាត់ប្រឡាយ ឬស្ទឹងនៃបង្គោល T413-T414


Draft

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ផែនទីបង្ហាញអគ្គិសនីដែលជាប់នឹងប្រព័ន្ធផ្លូវទឹកបំផុត

MAP OF POWER TOWER NEXT TO HYDROLOGY



Draft

គម្រោង: ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីភ្នំពេញ
PROJECT: HIGH VOLTAGE 230KV TRANSMISSION LINE PROJECT FROM STUNGHAV TO WEST-PHNOM PENH SUB-STATION

រូបភាព៤.១៨៖ បង្គោលខ្សែភ្លើងដែលមានទីតាំងជាប់នឹងប្រព័ន្ធផ្លូវទឹកខ្លាំងបំផុត

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូងលើគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍អគ្គិសនីខាងលិចភ្នំពេញរបស់ក្រុមហ៊ុន

Draft

៤.៣ ការសិក្សាធនធានជីវសាស្ត្រ

៤.៣.១ ការសិក្សាគម្របព្រៃឈើ

ក្នុងការសិក្សាស្ថិតិនៃផ្ទៃដីសរុបរបស់ប្រភេទគម្របព្រៃឈើនីមួយៗ ត្រូវបានសិក្សាដោយការប្រើប្រាស់នូវកម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងការវិភាគពង្រីក (Buffer) ៣០ម៉ែត្រ និង៥០ម៉ែត្រសងខាងនៃគន្លងខ្សែបញ្ជូន ដើម្បីទទួលបាននូវទិន្នន័យនៃប្រភេទគម្របព្រៃឈើសរុបដែលខ្សែបញ្ជូនឆ្លងកាត់។ បន្ថែមពីនេះ រាល់នូវលេខសម្គាល់បង្គោលភ្លើង និងប្រភេទគម្របព្រៃឈើ ដែលបង្គោលអគ្គិសនីត្រូវបានសាងសង់ត្រូវបានរាយនាមក្នុងការសិក្សានេះ។ ការសិក្សានេះត្រូវបានគណនាដោយប្រើប្រាស់នូវគម្របព្រៃឈើ ២០១០ (ទិន្នន័យរបស់រដ្ឋបាលព្រៃឈើ) ដែលទិន្នន័យនេះមាននូវគម្របព្រៃឈើចំនួន ៨ប្រភេទ រួមមាន៖ ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ប្រភេទព្រៃផ្សេងៗ ដីពុំមានគម្របព្រៃ ព្រៃឫស្សី ព្រៃគម្លោតស្តួត និងព្រៃគម្លោតបៃតង។

តាមរយៈការវិភាគពង្រីក ៣០ម៉ែត្រសងខាងគន្លងខ្សែបញ្ជូន បានបង្ហាញថាគន្លងខ្សែបញ្ជូនឆ្លងកាត់ប្រភេទគម្របព្រៃឈើចំនួន០៦ប្រភេទផ្សេងៗគ្នា រួមមានប្រភេទគម្របព្រៃ ដីពុំមានគម្របព្រៃ មានទំហំ៨៦៥ហិកតា ព្រៃល្បោះមានទំហំ៤២ហិកតា ព្រៃស្រោងមានទំហំ៣៨ហិកតា ប្រភេទព្រៃផ្សេងៗ មានទំហំ៣០ហិកតា ព្រៃគម្លោតបៃតងមានទំហំ១៧ហិកតា និងព្រៃពាក់កណ្តាលស្រោងមានទំហំ ១៤ហិកតា។

កាន់តែជាក់ច្បាស់ជាងនេះទៅទៀត ទំហំព្រៃសរុបនៃប្រភេទគម្របព្រៃឈើតាមបណ្តាខេត្តនីមួយៗដែលគន្លងខ្សែបញ្ជូនឆ្លងកាត់ ត្រូវបានរៀបរាប់ដូចខាងក្រោម៖

- ខេត្តកំពង់ស្ពឺ៖ គន្លងខ្សែបញ្ជូនបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៥ប្រភេទដែលរួមមានដីពុំមានគម្របព្រៃមានទំហំ ៤៤៤ ហិកតា ព្រៃល្បោះមានទំហំ៤២ហិកតាព្រៃគម្លោតបៃតងមានទំហំ ១៦ហិកតា ព្រៃស្រោងមានទំហំ ៩ហិកតា និងប្រភេទព្រៃផ្សេងៗ មានទំហំ ៥ហិកតា។
- ខេត្តកោះកុង៖ គន្លងខ្សែបញ្ជូនត្រូវបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៥ប្រភេទដែលរួមមាន ដីពុំមានគម្របព្រៃមានទំហំ៣២៩ហិកតា ព្រៃស្រោងមានទំហំ២៩ហិកតា ប្រភេទព្រៃផ្សេងៗ មានទំហំ១៨ហិកតា ព្រៃពាក់កណ្តាលស្រោងមានទំហំ៨ហិកតា និងព្រៃគម្លោតបៃតងមានទំហំ២ហិកតា។

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ខេត្តព្រះសីហនុ៖ គន្លងខ្សែបញ្ជូនត្រូវបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៤ប្រភេទ ដែលរួមមាន ដីពុំមានគម្របព្រៃមានទំហំ៩១ហិកតា ប្រភេទព្រៃផ្សេងៗមានទំហំ៦ហិកតា ព្រៃពាក់កណ្តាលស្រោងមានទំហំ៦ហិកតា និងព្រៃស្រោងមានទំហំ ០,០២៨៦ហិកតា។


ចំពោះការវិភាគពង្រីក៥០ម៉ែត្រសងខាងគន្លងខ្សែបញ្ជូន បានបង្ហាញថាគន្លងខ្សែបញ្ជូនឆ្លងកាត់ប្រភេទគម្របព្រៃឈើចំនួន៦ប្រភេទផ្សេងៗគ្នា ដែលរួមមានដីពុំមានគម្របព្រៃមានទំហំ១.៤៤០ ហិកតា ព្រៃល្បាះមានទំហំ៧១ហិកតា ព្រៃស្រោងមានទំហំ៦៣ហិកតា ប្រភេទព្រៃផ្សេងៗ មានទំហំ ៥១ហិកតាព្រៃពាក់កណ្តាលស្រោងមានទំហំ២៨ហិកតា និងព្រៃគម្ពោតបៃតងមានទំហំ២៣ហិកតា។

ទំហំព្រៃសរុបនៃប្រភេទគម្របព្រៃឈើតាមបណ្តាខេត្តនីមួយៗ ដែលគន្លងខ្សែបញ្ជូនឆ្លងកាត់ត្រូវបានរៀបរាប់ដូចខាងក្រោម៖

- ខេត្តកំពង់ស្ពឺ៖ គន្លងខ្សែបញ្ជូនត្រូវបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៥ប្រភេទ ដែលរួមមាន ដីពុំមានគម្របព្រៃមានទំហំ ៧៤១ហិកតា ព្រៃល្បាះមានទំហំ៧១ហិកតា ព្រៃគម្ពោតបៃតងមានទំហំ២៦ហិកតា ព្រៃស្រោងមានទំហំ១៥ហិកតា និងប្រភេទព្រៃផ្សេងៗ មានទំហំ៩ហិកតា។
- ខេត្តកោះកុង៖ គន្លងខ្សែបញ្ជូនត្រូវបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៥ប្រភេទ ដែលរួមមានប្រភេទគម្របព្រៃឈើ ដីពុំមានគម្របព្រៃ មានទំហំ៥៤៨ហិកតា ព្រៃស្រោង មានទំហំ៤៨ហិកតា ប្រភេទព្រៃផ្សេងៗមានទំហំ៣២ហិកតា ព្រៃពាក់កណ្តាលស្រោង មានទំហំ១៤ហិកតា និងព្រៃគម្ពោតបៃតង មានទំហំ៣ហិកតា។
- ខេត្តព្រះសីហនុ៖ គន្លងខ្សែបញ្ជូនត្រូវបានឆ្លងកាត់នូវប្រភេទគម្របព្រៃឈើចំនួន០៤ប្រភេទ ដែលរួមមានប្រភេទគម្របព្រៃឈើ ដីពុំមានគម្របព្រៃមានទំហំ១៥២ហិកតា ប្រភេទព្រៃផ្សេងៗមានទំហំ១០ហិកតា ព្រៃពាក់កណ្តាលស្រោងមានទំហំ១០ហិកតា និងព្រៃស្រោងមានទំហំ០,១២០៣ហិកតា។


ក្នុងចំណោមបង្គោលភ្លើងសរុបចំនួន៤២៦បង្គោល ក្នុងនោះមានបង្គោលខ្សែភ្លើងចំនួន៣៦៦ បង្គោលត្រូវបានសាងសង់លើតំបន់ដីពុំមានគម្របព្រៃ១៦បង្គោល ត្រូវបានសាងសង់លើតំបន់ព្រៃល្បាះ១៦បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃស្រោង១៣បង្គោល ត្រូវបានសាងសង់លើតំបន់ប្រភេទព្រៃផ្សេងៗ ៨បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃគម្ពោតបៃតង និង៧បង្គោលត្រូវបានសាងសង់លើ តំបន់ព្រៃពាក់កណ្តាលស្រោង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.១៩៖ ស្ថានភាពគម្របព្រៃឈើ២០១០ដែលមានទីតាំងជាប់នឹងគន្លងខ្សែបញ្ជូន


#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



Draft

រូបភាព២០៖ ស្ថានភាពគម្របព្រៃឈើ ២០១០ ដែលត្រូវបានរងនូវផលប៉ះពាល់តាមរយៈការវិភាគ៣០ម៉ែត្រ និង៥០ម៉ែត្រ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



Draft

រូបភាព៤.២១៖ ស្ថានភាពគម្របព្រៃឈើ ២០១០ ដែលមានទីតាំងជាប់នឹងគន្លងខ្សែបញ្ជូនក្នុងខេត្តព្រះសីហនុ

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

Draft

៤.៣.២ ការសិក្សាអំពីសត្វ

ជាលទ្ធផលនៃការពិភាក្សាក្រុមចំនួន០២ក្រុម នៅក្នុងភូមិស្ទឹងច្រាល និងភូមិទីជ្រាំមួយ ដែលជាភូមិស្ថិតនៅជិតតំបន់យាយមៅដែលជាតំបន់ដែលនឹងមានគន្លងខ្សែឆ្លងកាត់។ បន្ទាប់ពីការពិភាក្សាក្រុមដោយមានការបង្ហាញសៀវភៅប្រភេទសត្វព្រៃទៅដល់ប្រជាជននៅក្នុងការកំណត់ និងពិភាក្សាពីប្រភេទសត្វព្រៃ។ ជាលទ្ធផលពីការកត់ត្រាទិន្នន័យនៅទីវាលបានបង្ហាញថា ប្រភេទថនិកសត្វមានចំនួន១០ប្រភេទ ល្មូនមានចំនួន០៦ប្រភេទ បក្សីមានចំនួន០៨ប្រភេទ និងថលជលិកសត្វ ឬពពួកកង្កែបមានចំនួន០៤ប្រភេទ។ ជាសរុបការកត់ត្រាទិន្នន័យសត្វព្រៃក្នុងតំបន់សិក្សាមានចំនួន ២៨ប្រភេទ។ សម្រាប់រយៈពេលនៃការកត់ត្រារបស់ប្រជាជនទៅលើការសិក្សាពីសត្វវិញមានរយៈពេល៥ឆ្នាំ។

តារាង៤.១៖ ចំនួននៃប្រភេទសត្វក្នុងតំបន់ប្រវត្តិសាស្ត្រយាយមៅ

ប្រភេទ	ឆ្នាំសិក្សា (២០១៥)
	ចំនួន (ប្រភេទ)
ថនិកសត្វ	១០
ល្មូន	៦
បក្សី	៨
ថលជលិកសត្វ ឬពពួកកង្កែប	៤
សរុប	២៨

ក. ប្រភេទថនិសត្វ

ប្រភេទថនិកសត្វចំនួន ១០ប្រភេទ ត្រូវបានជួបប្រទះ តាមរយៈដានសម្លេង លាមក និងជួបក្នុងកំឡុងពេលដើរអង្កេត ។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានប្រភេទថនិកសត្វចំនួន០២ប្រភេទ ដែលកម្រ គឺដំរី និងខ្លា។ តែលើតាមបញ្ជីក្រហម IUCN Red List បង្ហាញថា ខ្លា និងដំរី ជាប្រភេទសត្វជិតផុតពូជ (EN) ស្វាក្តាម ទូច និងកាំប្រម៉ា ជាប្រភេទរងការគម្រាមកំហែង និងជ្រូកព្រៃ ទន្សាយ ប្រជៀវ កំប្រុកពណ៌ ជាប្រភេទសត្វដែលមានដោយបង្គួរ។



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៤.២៖ ប្រភេទថនិកសត្វដែលទទួលរងការគម្រាមកំហែង និងមានដោយបង្គួរ ក្នុងតំបន់គម្រោង

ល.រ	ប្រភេទសត្វ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	MAFF 2007	IUCN
១	ខ្លា	Tiger		R	EN
២	ជ្រូកព្រៃ	Wild Pig	Sus scrofa	C	LC
៣	ឈ្លូស	Red Muntjac	Muntiacus Muntjak	C	LC
៤	ស្វាក្តាម	Long-tailed Macaque	Macaca Fascicularis	C	NT
៥	ដំរី	Elephant		R	EN
៦	ទន្សាយ	Rabbit		C	LC
៧	ទូច	Gibbon		C	NT
៨	ប្រជៀវ	Bat		C	LC
៩	កាំប្រម៉ា	Ma radius		C	NT
១០	កំប្រុកពណ៌	Variable Squirrel	Callosciurus Finlaysonii	C	LC

ចំណាំ៖ C = Common (មានដោយបង្គួរ), R = Rare (មានដោយកម្រ), LC = Least of Concern (ប៉ះពាល់តិចតួច), EN = Endanger (ប៉ះពាល់ខ្លាំង), NT = Nearly Threat (ជិតផុតពូជ)

ខ. ប្រភេទល្មូន

ប្រភេទល្មូនមានចំនួន០៦ប្រភេទ ត្រូវបានជួបប្រទះតាមរយៈដាន សម្លេង និងឃើញក្នុងកំឡុងពេលដើរអង្កេត។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ប្រភេទល្មូនទាំងនោះជាប្រភេទមានដោយបង្គួរ។

តារាង៤.៣៖ ប្រភេទល្មូនដែលមានដោយបង្គួរ ក្នុងតំបន់គម្រោង

ល.រ	ប្រភេទសត្វ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	MAFF 2007	IUCN
១	បង្គួយ	Moustached Lizard	Calotes mystaceus	C	-
២	ត្រកូត	Bengel Monitor	Varanus bengalensis	C	LC
៣	ពស់ថ្លាន់	Python		C	-

Draft

៤	ពស់វែងនោម	-	-	-	-
៥	ពស់វែងដំបូក	-	-	-	-
៦	ថ្លែន	Long-tailed Sun Skink	Mabuya longicaudata	C	-

ចំណាំ៖ C = Common (មានដោយបង្គួរ), R = Rare (មានដោយកម្រ), LC = Least of Concern (ប៉ះពាល់តិចតួច), EN = Endanger (ប៉ះពាល់ខ្លាំង), NT = Nearly Threat (ជិតផុតពូជ)

គ. ប្រភេទបក្សី

ប្រភេទសត្វស្លាបមានចំនួន ៩ប្រភេទ ត្រូវបានជួបប្រទះ តាមរយៈសម្លេង ជួប និងស្លាកស្នាមផ្សេងៗ ក្នុងកំឡុងពេលដើរអង្កេត។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានប្រភេទបក្សីមួយប្រភេទដែលស្ថិតក្រោមការគម្រាមកំហែង គឺកេងកងធំ ខណៈ ០៧ប្រភេទផ្សេងទៀតត្រូវបានបង្ហាញថាស្ថានភាពរបស់វាមិនសូវសម្បូរទេក្នុងប្រទេសកម្ពុជា។

តារាង៤.៤៖ ប្រភេទសត្វស្លាបដែលកម្រក្នុងតំបន់គម្រោង

ល.រ	ប្រភេទសត្វ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	ស្ថានភាពនៅកម្ពុជា	IUCN
១	សារិកាកែវ	Hill Myna	Gracula religiosa	r	LC
២	លលកបាយ	Soptted Dove	Streptopelai chinensis	r	
៣	សេក	Parrot		r	
៤	មាន់ព្រៃ	Red Junglefowl	Gallus gallus	r	LC
៥	ចាបតេតព្រៃ	Dark-necked tailorbird	Orthotomus atrogularis	C	LC
៦	ទាទឹក	-			-
៧	ញ៉ាំង	Wreathed Hornbill	Aceros undulatus	r	
៨	កេងកងតូច	Oriental Pied	Anthracoceros	r	

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

		Hornbill	albirostris		
៩	កេងកងធំ	Great Hornbill	Buceros bicornis	r	NT

ចំណាំ៖ C = Common (មានដោយបង្គួរ), R = Rare (មានដោយកម្រ), LC = Least of Concern (ប៉ះពាល់តិចតួច), EN = Endanger (ប៉ះពាល់ខ្លាំង), NT = Nearly Threat (ជិតផុតពូជ)

ឃ. ប្រភេទថលជលិកសត្វ ឬពពួកកង្កែប

ប្រភេទថលជលិកសត្វ ឬពពួកកង្កែបមានចំនួន ៤ប្រភេទ ត្រូវបានប្រទះឃើញតាមរយៈដានសម្លេង និងការជួបប្រទះឃើញ ក្នុងកំឡុងពេលអង្កេត ហើយចំនួនថលជលិកសត្វ ឬពពួកកង្កែប ៤ប្រភេទត្រូវបានបង្ហាញ និងកត់ត្រា។ ក្នុងនោះផងដែរ ថលជលិកសត្វ ឬពពួកកង្កែប មួយប្រភេទកំពុងស្ថិតក្នុងការគម្រាមគំហែង គឺកង្កែបព្រៃ។

តារាង៤.៥៖ ប្រភេទថលជលិកសត្វក្នុងតំបន់គម្រោង

ល.រ	ប្រភេទសត្វ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	IUCN
១	កង្កែបភូប	Rugulose Frog	Hoplobatrachus Rugulosus	LC
២	កង្កែបអាចម៉ូគោ	Paddy Frog	Fejervarya Limnocharis	LC
៣	កង្កែបព្រៃ	Marten's Frog	Hylarana Mortenseni	NT
៤	គឹងគក់	..	Duttaphyrne Melanostictus	LC

ចំណាំ៖ C = Common (មានដោយបង្គួរ), R = Rare (មានដោយកម្រ), LC = Least of Concern (ប៉ះពាល់តិចតួច), EN = Endanger (ប៉ះពាល់ខ្លាំង), NT = Nearly Threat (ជិតផុតពូជ)

៤.៤ ការសិក្សាស្ថានភាពសង្គម-សេដ្ឋកិច្ច

ការសិក្សាអំពីស្ថានភាពសេដ្ឋកិច្ច-សង្គម មានគោលបំណងប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធទៅនឹងស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ប្រជាជនមូលដ្ឋានដែលរស់នៅក្នុង និងក្បែរតំបន់គម្រោង។ ព័ត៌មានទាំងនេះ អាចនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការវិភាគ និងវាយតម្លៃអំពី

Draft

សក្តានុពលនៃផលប៉ះពាល់ផ្សេងៗ ដែលអាចនឹងបង្កឡើងដោយសារសកម្មភាពគម្រោងទាំងមុនពេលកំឡុងពេល និងក្រោយពេលដំណើរការគម្រោង។ មិនតែប៉ុណ្ណោះ ព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច-សង្គម មានសារៈសំខាន់សម្រាប់ការកំណត់ និងលើកឡើងនូវវិធានការកាត់បន្ថយនានាដែលអាចនឹងឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ និងមានប្រសិទ្ធិភាព។

មាតិកាសំខាន់ៗក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានផ្នែកសេដ្ឋកិច្ច-សង្គមរួមមាន៖

- ប្រជាសាស្ត្រ និងលំនៅដ្ឋាន
- ស្ថានភាពសេដ្ឋកិច្ច
- ការអប់រំ
- ការប្រើប្រាស់ទឹក
- ការប្រើប្រាស់ថាមពល
- សុខភាពសាធារណៈ
- ហេដ្ឋារចនាសម្ព័ន្ធ
- ប្រពៃណី វប្បធម៌ និងទំនៀមទម្លាប់

៤.៤.១ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានផ្នែកសេដ្ឋកិច្ច-សង្គម បានប្រើប្រាស់វិធីសាស្ត្រពីរយ៉ាងគឺវិធីសាស្ត្របែបបរិមាណវិស័យ និងវិធីសាស្ត្របែបគុណវិស័យដោយប្រើប្រាស់ទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំសម្រាប់ធ្វើការវិភាគ និងវាយតម្លៃ៖

- **ទិន្នន័យបឋម៖** ទិន្នន័យបឋម បានមកពីការសម្ភាសផ្ទាល់ជាមួយអាជ្ញាធរភូមិ-ឃុំ និងប្រជាជនតាមលក្ខណៈគ្រួសារដែលរស់នៅក្នុង ឬក្បែរតំបន់គម្រោង។

- **ទិន្នន័យបន្ទាប់បន្សំ៖** ទិន្នន័យបន្ទាប់បន្សំ បានមកពីការធ្វើសំយោគបណ្ណាល័យសាស្ត្រ និងឯកសាររបាយការណ៍នានាដែលពាក់ព័ន្ធទៅនឹងស្ថានភាពភូមិ-ឃុំដែលនៅក្នុង ឬក្បែរតំបន់គម្រោង ដែលបានធ្វើបច្ចុប្បន្នភាព និងបោះពុម្ពចុងក្រោយគេបំផុត។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

Draft

៤.៤.២ ការកំណត់ចំនួនសំណាក

គម្រោងតភ្ជាប់បណ្តាញអគ្គិសនី ដែលមានតង់ស្យុង ២៣០គីឡូវ៉ុលពីស្រុកស្ទឹងហាវតភ្ជាប់មករាជធានីភ្នំពេញមានចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់សរុបចំនួន១.៣១៨គ្រួសារ ក្នុង១៩ឃុំ ០៧ស្រុក និង០៣ខេត្ត។ ដូចនេះ ក្រុមសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានផ្នែកសេដ្ឋកិច្ច-សង្គម បានកំណត់ជ្រើសរើសគ្រួសារមួយចំនួន សម្រាប់ធ្វើការសម្ភាសអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ពួកគេ។


ទិន្នន័យដែលបានប្រមូល ត្រូវបញ្ចូលក្នុងកម្មវិធី Microsoft Excel 2013 រួចបម្លែងទៅក្នុងកម្មវិធី STATA 13.0 ដើម្បីធ្វើការវិភាគស្ថិតិពណ៌នារួមមានប្រែកង់ មធ្យម ភាគរយ និងគម្លាតស្តង់ដារ។

៤.៤.៣ លទ្ធផលនៃការសិក្សា

៤.៤.៣.១ ប្រជាសាស្ត្រ និងលំនៅដ្ឋាន

តាមរយៈការសម្ភាសជាមួយប្រជាជនដែលទទួលរងផលប៉ះពាល់មួយភាគតូច ក្នុងឃុំទាំង១៩ បានបង្ហាញថាអ្នកឆ្លើយតបជាស្ត្រីមានប្រមាណ៣០ភាគរយ និងអ្នកឆ្លើយតបជាបុរសមានប្រមាណ៧០ភាគរយ។ លទ្ធផលនៃការសិក្សាបានបង្ហាញថា បុរសជាមេគ្រួសារមានប្រមាណ៦០ភាគរយ និងស្ត្រីជាមេគ្រួសារមានប្រមាណ៤០ភាគរយ។ តាមរយៈតួលេខនេះបានបង្ហាញថា មេគ្រួសារជាបុរសមានច្រើនជាងមេគ្រួសារជាស្ត្រីហើយការសម្រេចចិត្តភាគច្រើន គឺលើបុរសដែលជាស្វាមីជាអ្នកធ្វើសេចក្តីសម្រេចចិត្ត។ ក្នុងកំឡុងពេលចុះធ្វើការសម្ភាសសាកសួរព័ត៌មាន ក្រុមសិក្សាបានសង្កេតឃើញថា តាមលំនៅដ្ឋាននីមួយៗ ស្ត្រីជាកម្លាភាគច្រើនធ្វើការនៅក្នុងផ្ទះ ហើយបុរសជាស្វាមីជាអ្នកស្វែងរកប្រាក់ចំណូលជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។

លទ្ធផលនៃការសិក្សាបានបង្ហាញពីរបាយអាយុនៃអ្នកឆ្លើយតបជាបីក្រុមគឺ៖ អ្នកឆ្លើយតបដែលមានអាយុពីចន្លោះ២០ឆ្នាំ ទៅ៣៥ឆ្នាំមានប្រមាណ៣៤ភាគរយ ចន្លោះអាយុ៣៦ឆ្នាំ ទៅ៤៩ឆ្នាំមានប្រមាណ៥០ភាគរយ និងអាយុច្រើនជាង៥០ឆ្នាំមានប្រមាណ១៦ភាគរយ (ក្រាហ្វិក ៤.១)។




ក្រាហ្វិក៤.១៖ របាយអាយុនៃអ្នកឆ្លើយតប

ចំណែកទំហំគ្រួសារក្នុងភូមិក្នុងមួយគ្រួសារជាមធ្យមមានសមាជិកចំនួន០៥នាក់។ គ្រួសារដែលមានសមាជិកតិចបំផុតមានចំនួន០២នាក់ និងគ្រួសារមានសមាជិកច្រើនបំផុតមាន១២នាក់។ តាមរយៈទិន្នន័យនេះយើងអាចសន្និដ្ឋានបានថា ប្រជាជនដែលស្ថិតនៅក្បែរតំបន់គម្រោង គឺជាប្រភេទគ្រួសារធំដែលមានតម្រូវការក្នុងជីវភាពប្រចាំថ្ងៃខ្ពស់។ ភាគច្រើននៃប្រជាជនដែលបានសម្ភាសន៍ប្រមាណ ៧៦ ភាគរយបានអះអាងថាពួកគាត់បានប្រើប្រាស់ដីធ្លីសម្រាប់តាំងលំនៅដ្ឋានរស់នៅ និងបង្កបង្កើនផលចាប់តាំងពីឆ្នាំ១៩៧០ ឬមុនសម័យរបបប្រល័យពូជសាសន៍ប៉ុលពតមកម្លេះ។ ចំណែកឯប្រជាជនប្រមាណ២៤ភាគរយ ក៏បានអះអាងថាពួកគាត់បានប្រើប្រាស់ដីធ្លីសម្រាប់តាំងលំនៅដ្ឋានរស់នៅ និងបង្កបង្កើនផលយ៉ាងហោចណាស់រយៈពេល៩ឆ្នាំមកហើយ។ ទន្ទឹមនឹងនេះលទ្ធផលនៃការសិក្សាបានបង្ហាញថាក្នុងចំណោមប្រជាជនដែលបានសម្ភាសទាំងអស់គឺជាជនជាតិខ្មែរ និងមិនមានជនជាតិដើមភាគតិចនោះទេ។

Draft

ស្ថានភាពលំនៅដ្ឋានបច្ចុប្បន្នរបស់ប្រជាជនមានលក្ខណៈខុសគ្នាទៅតាមតំបន់ និងទីតាំងរស់នៅរបស់គ្រួសារនីមួយៗ។ លទ្ធផលនៃការសម្ភាសបានបង្ហាញថា ប្រភេទផ្ទះរបស់ប្រជាជនដែលមានលំនៅដ្ឋានអាចនឹងទទួលរងផលប៉ះពាល់ដោយសារវត្តមានរបស់គម្រោង រួមមានប្រភេទផ្ទះដំបូលប្រក់ស្បូវចំនួន១៧,៤ភាគរយ ប្រភេទផ្ទះដំបូលប្រក់ស័ង្កសីចំនួន៦១,៤ភាគរយ ប្រភេទផ្ទះដំបូលប្រក់ក្បឿងចំនួន១៣ភាគរយ និងប្រភេទផ្ទះថ្មចំនួន៨,២ភាគរយ។ ប្រភេទផ្ទះប្រក់ស័ង្កសីមានភាគរយខ្ពស់ជាងគេ និងបន្ទាប់មកប្រភេទផ្ទះប្រក់ស្បូវ ដែលអាចឆ្លុះបញ្ចាំងអំពីកម្រិតជីវភាពរបស់ប្រជាជនមានលក្ខណៈពីទាបទៅមធ្យម (ក្រាហ្វិក ៤.២)។



ក្រាហ្វិក៤.២៖ ប្រភេទផ្ទះរបស់អ្នកឆ្លើយតប


Draft

៤.៤.៣.២ ស្ថានភាពសេដ្ឋកិច្ច

ក. មុខរបរ

ការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់សិក្សា មានលក្ខណៈខុសគ្នាច្រើនបែបសណ្ឋានទៅតាមគ្រួសារនីមួយៗ។ តាមរយៈលទ្ធផលនៃការសិក្សាបានបង្ហាញឱ្យឃើញថា មុខរបរចម្បងៗរបស់ប្រជាជនដែលបានសម្ភាសន៍រួមមានអាជីវករមាន១៥,៤ភាគរយ ធ្វើស្រែមាន៥០,៦ភាគរយ អ្នកចម្ការមាន៧,៥ភាគរយ ចិញ្ចឹមសត្វមាន៤,៧ភាគរយ កម្មករមាន១២,៤ភាគ

រយ មន្ត្រីរាជការមាន២,៥ភាគរយ អ្នករត់ម៉ូតូឌុបមាន៤,៨ភាគរយ និងអ្នកនេសាទមាន២,១ភាគរយ (ក្រាហ្វិក៤.៣)។ លទ្ធផលនេះបានបង្ហាញថា ភាគច្រើននៃអ្នកឆ្លើយតបមានមុខរបរចម្បងធ្វើស្រែ។ ក្រៅពីនេះ ពួកគេក៏មានមុខរបរបន្ទាប់បន្សំមួយចំនួនទៀតដូចជាធ្វើការងារសំណង់ និងចិញ្ចឹមសត្វនៅពេលទំនេរពីការងារធ្វើស្រែចម្ការ។



ក្រាហ្វិក៤.៣៖ ប្រភេទមុខរបរចម្បងរបស់អ្នកឆ្លើយតប

Draft

ខ. ប្រាក់ចំណូល

ប្រាក់ចំណូល ជាសូចនាករមួយដែលអាចឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌសេដ្ឋកិច្ច និងសុខុមាលភាពរបស់គ្រួសារនីមួយៗ។ តាមរយៈលទ្ធផលនៃការសម្ភាសគ្រួសារដែលរស់នៅក្បែរតំបន់គម្រោងអាចរកប្រាក់ចំណូលជាមធ្យមបាន ៧៧១.៤០០ រៀល/ខែ (១៩២,៨៥ដុល្លា/ខែ)។ ចំពោះគ្រួសារអាចរកប្រាក់ចំណូលបានច្រើនបំផុតគឺ ២.៥៩២.៤០០រៀល/ខែ (៦៤៨,១ដុល្លា/ខែ) ហើយគ្រួសារដែលអាចរកប្រាក់ចំណូលតិចបំផុតគឺ១២៨.៨០០រៀល/ខែ (៣២,២ដុល្លា/ខែ)។ គម្លាតស្តង់ដារនៃប្រាក់ចំណូលរបស់គ្រួសារនីមួយៗគឺ៥៥៤.៥០០រៀល/ខែ (១៣៨,៦៣ដុល្លា/ខែ)។ លទ្ធផលនៃការសិក្សាបានបង្ហាញថា គម្លាតប្រាក់ចំណូលរបស់គ្រួសារនីមួយៗមានតម្លៃខ្ពស់ ដែលបង្ហាញអំពីគម្លាតធ្ងាយរវាងគ្រួសារដែលមានប្រាក់ចំណូលខ្ពស់ និងគ្រួសារដែលមានប្រាក់ចំណូលទាប។ តាមរយៈការសង្កេតរបស់ក្រុមសិក្សា

ស្រាវជ្រាវ ក្រុមគ្រួសារដែលមានប្រាក់ចំណូលខ្ពស់ភាគច្រើនប្រកបមុខរបរជាអាជីវករ និងគ្រួសារដែលមានទំហំដីធំសម្រាប់ធ្វើស្រែចម្ការ។

តារាង ៤.៦៖ ប្រាក់ចំណូលរបស់គ្រួសារដែលបានសម្ភាសន៍

ប្រាក់ចំណូល	គិតជារៀល/ខែ	គិតជាដុល្លា/ខែ
ខ្ពស់បំផុត	២.៥៩២.៤០០	៦៤៨,១
មធ្យម	៧៧១.៤០០	១៩២,៨៥
ទាបបំផុត	១២៨.៨០០	៣២,២
គម្លាតស្តង់ដារ	៥៥៤.៥០០	១៣៨,៦៣

គ. ប្រាក់ចំណាយ

ការចំណាយរបស់ប្រជាជនគឺអាស្រ័យលើតម្រូវការបឋម និងតម្រូវការបន្ទាប់បន្សំផ្សេងៗគ្នារបស់គ្រួសារនីមួយៗ។ ការចំណាយទាំងនោះរួមមានការចំណាយលើម្ហូបអាហារ ការព្យាបាល មធ្យោបាយធ្វើដំណើរ ថាមពលសម្រាប់ចម្អិន ថាមពលសម្រាប់បំភ្លឺ និងការសិក្សារបស់កូនជាដើម។ លទ្ធផលសិក្សាបង្ហាញថា ប្រជាជនដែលបានសម្ភាសន៍បានចំណាយប្រាក់សរុបជាមធ្យម ៦៧៣.៩០០ រៀល/ខែ (១៦៨,៤៨ដុល្លា/ខែ)។ ចំពោះគ្រួសារដែលបានចំណាយប្រាក់តិចបំផុតគឺ ១២៦.០០០រៀល/ខែ (៣១,៥ដុល្លា/ខែ) និងគ្រួសារដែលបានចំណាយប្រាក់ច្រើនបំផុតគឺ ១.៣១៧.០០០រៀល/ខែ (៣២៩,២៥ដុល្លា/ខែ)។ គម្លាតស្តង់ដារនៃការចំណាយរបស់គ្រួសារនីមួយៗគឺ ២៩៧.០០០រៀល/ខែ (៧៤,២៥ដុល្លា/ខែ) (តារាង ៤.៧)។

តារាង ៤.៧៖ ប្រាក់ចំណាយរបស់គ្រួសារដែលបានសម្ភាសន៍

ប្រាក់ចំណាយ	គិតជារៀល/ខែ	គិតជាដុល្លា/ខែ
ខ្ពស់បំផុត	១.៣១៧.០០០	៣២៩,២៥
មធ្យម	៦៧៣.៩០០	១៦៨,៤៨
ទាបបំផុត	១២៦.០០០	៣១,៥
គម្លាតស្តង់ដារ	២៩៧.០០០	៧៤,២៥

Draft


ជាទូទៅ ការចំណាយមានទំនាក់ទំនងជាមួយប្រាក់ចំណូលប្រចាំខែ។ គ្រួសារដែលអាចរកប្រាក់ចំណូលបានខ្ពស់ឧទាហរណ៍ដូចជាអាជីវករ និងអ្នកធ្វើស្រែចម្ការ ទំនោរមានការចំណាយខ្ពស់ផងដែរ។ ទោះបីជាការចំណាយ និងចំណូលរបស់គ្រួសារដែលបានសម្ភាសន៍ប្រហាក់ប្រហែលគ្នាក៏ដោយ ប៉ុន្តែគម្លាតស្តង់ដារនៃការចំណាយ និងចំណូលមានទំហំធំទូលាយ។ នេះមានន័យថាចំណូល ចំណាយរបស់ប្រជាជនដែលបានសម្ភាសន៍ មានលក្ខណៈខុសគ្នាទៅតាមប្រភេទមុខរបរនីមួយៗ។ ម្យ៉ាងវិញទៀត យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា គ្រួសារដែលអាចរកប្រាក់ចំណូលបានខ្ពស់ មានការចំណាយច្រើនក្នុងគ្រួសារ ហើយគ្រួសារដែលអាចរកប្រាក់ចំណូលបានទាប មានការចំណាយតិចក្នុងគ្រួសារផងដែរ។

៤.៤.៣.៣ ការអប់រំ

ការអប់រំ ជាសូចនាករមួយដែលអាចវាស់វែងអំពីកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ និងរួមចំណែកលើកស្ទួយជីវភាពគ្រួសារឱ្យមានលក្ខណៈប្រសើរឡើងផងដែរ។ យោងតាមលទ្ធផលនៃការសម្ភាសបានបង្ហាញថា កម្រិតអប់រំរបស់ប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងនៅមានកម្រិតទាបនៅឡើយ។ កម្រិតអប់រំរបស់ប្រជាជនដែលមិនបានចូលរៀន ឬអនក្ខរកម្មមានចំនួន៣៧ភាគរយ កម្រិតបឋមសិក្សាមានចំនួន៤៧,៨ភាគរយ កម្រិតអនុវិទ្យាល័យមានចំនួន១២ភាគរយ និងវិទ្យាល័យមានចំនួន៣,៣ភាគរយ (ក្រាហ្វិក៤.៤)។ ក្នុងចំណោមប្រជាជនដែលបានសម្ភាសន៍ មិនមានគ្រួសារណាដែលបានទទួលការអប់រំត្រឹមកម្រិតសាកលវិទ្យាល័យនោះទេ។ ភាគច្រើននៃប្រជាជនដែលបានសម្ភាសន៍ធ្លាប់បានឆ្លងកាត់សម័យសង្គ្រាមក្នុងរបបប៉ុលពត ដែលជាហេតុធ្វើឱ្យពួកគាត់ភាគច្រើនមិនបានទទួលការអប់រំ ឬទទួលបានទាបត្រឹមកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




ក្រាហ្វិក ៤.៤៖ កម្រិតការអប់រំរបស់ប្រជាជនដែលបានសម្ភាសន៍

Draft

៤.៤.៣.៤ ការប្រើប្រាស់ទឹក

យោងតាមលទ្ធផលនៃការសម្ភាសបានបង្ហាញថា ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់គម្រោងបានប្រើប្រាស់ទឹកប្រមាណ០៥ប្រភពផ្សេងៗគ្នាគឺប្រភពទឹកទិញ ប្រភពទឹកអណ្តូង ប្រភពទឹកអូរ បឹង ស្ទឹង និងប្រភពទឹកពីបណ្តាញទឹកស្អាតឯកជន។ ប្រភពទឹកដែលប្រជាជនបានប្រើប្រាស់ច្រើនជាងគេគឺប្រភពទឹកភ្លៀង និងទឹកអូរ។ ប្រជាជនប្រមាណ៦៧,៥ភាគរយ បានទាញយកទឹកភ្លៀងសម្រាប់ប្រាស់ចម្អិនម្ហូបអាហារ និងប្រជាជនប្រមាណ៣០,៤ភាគរយ ទៀតបានទាញយកទឹកអូរ ឬស្ទឹងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជាបោកគក់ ងូត និងលាងសម្អាតផ្សេងៗ (ក្រាហ្វិក ៤.៥)។ ក្រៅពីនេះប្រជាជនប្រមាណ ១,៧ភាគរយ ទៀតបានទាញយកទឹកពីប្រភពអណ្តូង និងប្រជាជនប្រមាណ ០,៤ ភាគរយទៀត បានទាញយកទឹកពីបណ្តាញទឹកស្អាតឯកជនដើម្បីប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ។ ចំណែកឯប្រភពទឹកអណ្តូងស្ទប់ និងអណ្តូងលូត្រូវបានប្រជាជនប្រើប្រាស់បន្ទាប់បន្សំនៅរដូវប្រាំង បន្ថែមលើប្រភពទឹកពីទឹកភ្លៀង និងទឹកអូរ។ ជាទូទៅប្រជាជនបានដាំទឹកពីប្រភពនីមួយៗមុនពេលបរិភោគ ចំពោះបរិមាណទឹកប្រើប្រាស់សង្កេតឃើញថា ប្រជាជនអាចទាញយកទឹកមកប្រើប្រាស់គ្រប់គ្រាន់រនៅរដូវប្រាំង និងច្រើនលើសលប់ទាំងនៅក្នុងរដូវវស្សា។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



ក្រាហ្វិក ៤.៥៖ ប្រភពទឹកប្រើប្រាស់របស់ប្រជាជនដែលបានសម្ភាសន៍


៤.៤.៣.៤ ការប្រើប្រាស់ថាមពល

ក. ថាមពលសម្រាប់ចម្អិន

ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់សិក្សាបានប្រើប្រាស់ប្រភពថាមពលអុស ធ្យូង និងហ្គាសសម្រាប់ចម្អិនអាហារ។ លទ្ធផលនៃការសម្ភាសបានបង្ហាញថាប្រជាជនដែលបានប្រើប្រាស់អុសធ្យូងមានចំនួន៧២,៥ភាគរយ ប្រើប្រាស់ធ្យូងមានចំនួន១២,៥ភាគរយ ប្រើប្រាស់ហ្គាសមានចំនួន ១០,៧ភាគរយបានប្រើប្រាស់ហ្គាស និងប្រើប្រាស់ថាមពលអគ្គិសនីមានចំនួន៤,៣ភាគរយ សម្រាប់ចម្អិនម្ហូបអាហារ (ក្រាហ្វិក ៤.៦)។ យោងតាមលទ្ធផលនៃការសម្ភាសមិនមានគ្រួសារណាមួយដែលបានប្រើប្រាស់ឡជីវឧស្ម័នសម្រាប់ចម្អិនម្ហូបអាហារនោះទេ។ នេះបញ្ជាក់ថា បណ្តាញភ្លើងអគ្គិសនីនៅក្នុង និងក្បែរតំបន់សិក្សានៅមានភាពខ្វះខាតនៅឡើយ។ ដូចនេះវត្តមានរបស់គម្រោងក្នុងការតបណ្តាញខ្សែបញ្ជូនពីអនុស្ថានីយ៍ស្ទឹងហាវ តភ្ជាប់មកភាគខាងលិចនៃរាជធានីភ្នំពេញ នឹងអាចបំពេញតម្រូវការប្រើប្រាស់របស់ប្រជាជនមូលដ្ឋានដែលមានលំនៅដ្ឋាននៅក្នុង និងក្បែរបណ្តាញខ្សែបញ្ជូន។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



ក្រាហ្វិក៤.៦៖ ប្រភពថាមពលប្រើប្រាស់សម្រាប់ចម្អិនម្ហូបអាហារ

ខ. ថាមពលសម្រាប់បំភ្លឺ

តាមរយៈលទ្ធផលនៃការសម្ភាសបានបង្ហាញថា ប្រជាជនដែលមានលំនៅដ្ឋានក្បែរតំបន់គម្រោងប្រើថាមពលពីប្រភពម៉ាស៊ីនភ្លើងអគ្គិសនីផ្ទាល់ខ្លួន ភ្លើងអគ្គិសនីរដ្ឋ អាគុយ ចង្កៀង ប្រេងកាត និងពិលអាគុយសម្រាប់បំភ្លឺក្នុងលំនៅដ្ឋានរបស់ខ្លួន។ ប្រជាជនដែលបានប្រើប្រាស់ថាមពលពីប្រភពថាមពលសម្រាប់បំភ្លឺលំនៅដ្ឋានរួមមានភ្លើងអគ្គិសនីផ្ទាល់ខ្លួនមានចំនួន៣,៦ភាគរយ ភ្លើងអគ្គិសនីរដ្ឋមានចំនួន ៨,៥ភាគរយ អាគុយមានចំនួន៦៨,៥ភាគរយ .ចង្កៀងប្រេងកាតមានចំនួន១០,២ភាគរយ ពិលអាគុយមានចំនួន៩,៣ភាគរយ និងថាមពលពន្លឺព្រះអាទិត្យមានចំនួន១,៥ភាគរយ (ក្រាហ្វិក ៤.៧)។

Draft